## ជំពូកទី៨ : ការពិគ្រោះយោបល់សាធារណៈ

**១៤៣.** ដើម្បីរៀបចំរបាយការណ៍ ព្យាករណ៍ហេតុប៉ះពាល់ដល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច និងលើកអនុសាសន៏ជាមូលដ្ឋាន ដែលជាជំនួយក្នុងការសំរេចចិត្តថា តើគួរ ឬមិនគួរអនុម័តផ្តល់ដីសម្បទានទៅតាមការស្នើសុំរបស់វិនិយោគិននោះ ឬយ៉ាងណា ក្រុមការងារ **ហ្គ្រីន ខនសាល់ថិនស៊ី ហ្វឹម** បានធ្វើការពិគ្រោះយោបល់សាធារណៈជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក ប្រធាន និង អនុប្រធានមន្ទីរ ដែលពាក់ព័ន្ធ ព្រមទាំងតំណាងក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. សរុបចំនួន ១២ នាក់ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១០ ខ្លឹមសារនៃកំណត់ហេតុ របាយការណ៍ជួបប្រជុំនេះមាននៅក្នុងទំព័រ ១០២-១១៦ និងធ្វើឡើងនៅថ្ងៃ ១៥-១៦ ខែ កក្កដា ឆ្នាំ ២០១០ ដែលក្រុមការងារបានជួបផ្ទាល់ជាមួយនឹងអាជ្ញាធរមូលដ្ឋាន ដែលមានអភិបាលស្រុក មេឃុំ មេភូមិ អនុប្រធាន ភូមិ និងប្រជាជនសរុបចំនួន ០៥ នាក់។ ខ្លឹមសារនៃការជួបប្រជុំ នេះមាននៅក្នុងទំព័រ ១១៧-១១៨ បន្ទាប់ពី កំណត់ហេតុរបាយការណ៍ថ្នាក់ដឹកនាំខេត្ត។

Draft